ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ...សហវ.

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្ដាល សម្រាប់ការងារជួសជុលផ្លូវដោយក្រាលគ្រួសក្រហមចំនួន ០២ខ្សែ ប្រវែងសរុប ២១គ.ម ទទឹងខ្នងលើ ០៥ម កម្រាស់ ០,២ម ស្ថិតនៅក្នុងឃុំបឹងខ្យាង ឃុំព្រែករការ និងឃុំរលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល។

**យោង:** - លិខិតលេខ ១៩៨០ សហវ.អថ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ០៩២៧/១៦ ក.អ.ជ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្ដមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្ដាល ដើម្បីធ្វើការងារជួសជុលផ្លូវដោយក្រាលគ្រួសក្រហមចំនួន ០២ខ្សែ ប្រវែងសរុប ២១គ.ម ទទឹងខ្នងលើ ០៥ម កម្រាស់ ០,២ម ស្ថិតនៅក្នុងឃុំបឹងខ្យាង ឃុំព្រែករការ និងឃុំរលាំងកែន ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ក្នុងនោះ ÷

-ផ្លូវជាតិលេខ ២-វត្តស្វាក្រំ ឃុំបឹងខ្យាង និងឃុំព្រែករការ ស្រុកកណ្ដាលស្ទឹង ប្រវែង ១៤គ.ម ទទឹង ៥ម និង
-ផ្លូវរលាំងកែន-រការ ឃុំរលាំងកែន ស្រុកកណ្ដាល ស្ទឹង ប្រវែង ៧គ.ម ទទឹង ៥ម

ក្នុងតម្លៃសរុបចំនួន ១ ៤៦៦ ៥០០ ០០០រៀល (មួយប៊ីលាន បួនរយហុកសិបប្រាំមួយលាន ប្រាំរយពាន់រៀលគត់)ជាតម្លៃកិច្ចសន្យា។

ការផ្ទេរបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្ដមរដ្ឋមន្ត្រីមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្ដមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
រដ្ឋលេខាធិការ

**ជួ និរិទ្ធ**

**ចម្លងជូន:**
-ខុទ្ទកាល័យ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-អគ្គនាយកដ្ឋានថវិកា
-សាលាខេត្តកណ្ដាល
-មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្ដាល
-មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្ដាល
-ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 666 Fax : 855-23-427 798